# San Diego Unified School District

EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA 92103-2682


Terry B. Grier, Ed.D.
អគ្គស្នងការអប់រំ

ខែ មិនា ឆ្នាំ ២០០៨

មាតាបិតា/អ្នកអាណាព្យាបាលសិស្សជាទីរាប់អាន:

នាខែទីមួយដែលខ្ញុំបានបំរើការងារគឺមានការមមាញឹក និងមានកិច្ចការជាច្រើនដែលត្រូវដោះស្រាយ។ ខ្ញុំមានសេចក្តីរីករាយ និងមានពេលវេលាទៅពិនិត្យមើលនៅតាមសាលារៀនទាំងអស់ចំនួន ២០សាលា ហើយខ្ញុំនឹងមានគម្រោងទៅពិនិត្យមើលសាលារៀនជាច្រើនទៀតនាសប្តាហ៍ខាងមុខនេះ។

ខ្ញុំបានជួបជាមួយសិស្សមួយចំនួនទាំងអស់នៅក្នុងទីក្រុង San Diego ហើយមានការចាប់អារម្មណ៏អំពី ការយល់ឃើញរបស់សិស្សទាំងអស់សំរាប់អានាគត់របស់ខ្លួនឯង។ សិស្សរបស់យើងទាំងអស់មានបំណងបន្តការសិក្សាអោយបានខ្ពស់ ហើយយើងបន្ថែមដល់ការសិក្សាដល់សិស្សផងដែរ។ សិស្សសាលាវិទ្យាល័យបានប្រាប់ខ្ញុំថា ពួក៏គេមានបំណងចង់រៀនយកមុខវិជ្ជាចំណាត់ថ្នាក់ខ្ពស់ ព្រមទាំងមានបំណងចង់សិក្សាភាសាបរទេសផ្សេង។ និងយកស្នាក់បំរើការងារផងដែរ។ យោបល-មតិនេះមានសារៈសំខាន់ជាទីបំផុតដែលយើងត្រូវតែយកមកពិនិតិត្យសំរាប់សាលាវិទ្យាល័យនាពេលឆ្នាំខាងមុខនេះ។

នាមជាមាតាបិតា លោកអ្នកបានប្រាប់ខ្ញុំថា លោកអ្នកមានបំណងចង់បានការសិក្សាបន្ថែមសំរាប់កូនរបស់លោកអ្នក ហើយខ្ញុំសូមសន្យាជាមួយលោកអ្នកថា យើងនឹងស្តាប់តាមយោបល-មតិលោកអ្នក។

យើងកំពុងតែស្តាប់លោកអ្នកគាំទ្រថវិការសាលារៀន ហើយលោកអ្នកបានសាកសួរនូវអ្វីដែល " ខ្ញុំអាចជួយធ្វើទៅបាន " ។ លោកអ្នកបានសរសេរសំបុត្រ, ទូរស័ព្ទ, ដើរគាំទ្រថវិការសំរាប់សាលារៀន។ លោកអ្នកបានបំពេញយោបល-មតិជាសំដីដើម្បីអោយគេបានដឹងឮ នោះមានសារៈសំខាន់ជាទីបំផុត។ ពេលនេះបញ្ហាថវិការកំពុងតែធ្វើអោយបុគ្គលិកធ្វើការរដ្ឋនៅ Sacramento មានការចាប់អារម្មណ៏ជាខ្លាំង។

លោកអ្នកអាចធ្វើអ្វីទៀតបាន? លោកអ្នកត្រូវតែធ្វើការពិនិត្យមើលកូនលោកអ្នកអោយបានច្បាស់លាស់ដោយណែនាំកូនទៅសាលារៀនអោយបានរាល់ថ្ងៃ ពេលមិនមានជម្ងឺអ្វីមួយ។ ពេលសិស្សខានមិនបានមករៀន គឺសិស្សមិនបានរៀនមេរៀនអ្វីឡើយ។ ការមករៀនអោយបានរាល់ថ្ងៃបង្ហាញអោយឃើញថា នោះជាកម្លាំង និងណែនាំកូនសិក្សាអោយបានល្អនៅតាមសាលារៀន។

ការមករៀនមានការទាក់ទងនឹងថវិការ។ ច្បាប់ California បានប្រើប្រាស់ Average Daily Attendence (ADA) ដើម្បីផ្តល់ថវិការដល់សាលារៀន។ ពេលសិស្សម្នាក់អាកខានមិនមករៀនមួយថ្ងៃ សាលារៀននឹងបាត់បង់ថវិការចំនួន ៥០ដុល្លារ។ បើសាលារៀនរបស់កូនលោកអ្នកមានសិស្សចំនួន ២៥នាក់មិនមករៀនជារៀងរាល់ថ្ងៃក្នុងរយៈពេលមួយឆ្នាំ (១៨០ថ្ងៃ)សាលារៀននឹងបានបង់ថវិការចំនួន ២២៥០០០ដុល្លារ។ នោះមានន័យថា សាលារៀននឹងបាត់បង់កម្មវិធីបង្រៀនដ៏មានតម្លៃហើយសាលារៀនត្រូវការសម្ភារៈសិក្សា សំខាន់ជាងនេះ យើងត្រូវការលោកគ្រូ-អ្នកគ្រូ នឹងបុគ្គលិកសាលារៀនដើម្បីធ្វើការអប់រំសិស្ស - បុគ្គលិកទាំងនេះគឺយើងមានការទុកចិត្តយ៉ាងខ្លាំងក្លាក្នុងការផ្តល់គុណភាពអប់រំដល់កូនលោកអ្នកបានយ៉ាងប្រសើរ។

សូមអរគុណដល់លោកអ្នកដែលបានជួយជ្រោមជ្រែងដល់កូនលោកអ្នកនៅតាមផ្ទះជាងរៀងរាល់ថ្ងៃដើម្បីធ្វើការសិក្សាអោយជោគជ័យ។ ការធ្វើនេះអាចធ្វើអោយមានការរីកចំរើនបានល្អ។ ខ្ញុំសូមអរគុណដល់លោកអ្នកដែលធ្វើការគាំទ្រដល់សាលារៀនរបស់កូនលោកអ្នកដោយជួយធ្វើការខ្នះខ្នែង និងដោះស្រាយជាមួយគ្នា។

ដោយក្តីរាក់ទាក់បំផុត

Terry B. Grier, Ed.D.
អគ្គស្នងការអប់រំ